**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

## សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបើកសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២៣
## នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងភាគបាទក្រហមកម្ពុជា*
- *ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

ថ្ងៃនេះ ជាថ្មីម្តងទៀត ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកធ្វើជាអធិបតីក្នុងពិធីបើកសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២៣ ដ៏មហោឡារិកនេះ បន្ទាប់ពីកិច្ចប្រជុំពេញអង្គ ដែលបានប្រព្រឹត្តទៅកាលពីព្រឹកមិញ។ ក្នុងឱកាសដ៏ប្រពៃនេះ ខ្ញុំសូមសម្តែងនូវការស្វាគមន៍ និងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានដ៏មានតម្លៃរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅសកម្មភាពសម្រាប់ឆ្នាំ២០២៤ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជារបស់យើង។

ក្នុងរយៈពេលមួយឆ្នាំនេះ យើងបានបំពេញភារកិច្ចយ៉ាងសកម្មរួមគ្នា ដើម្បីឈានទៅបញ្ចប់ការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងដំណាក់កាលដែលស្ថានភាពជំនួយពីបរទេសធ្លាក់ចុះ។ នៅក្នុងរយៈពេលផ្ទេរដំណាក់កាលនេះ យើងទាំងអស់គ្នាចាប់ផ្តើមបំពេញតួនាទីក្នុងភាពជាម្ចាស់រួមនឹងការពង្រឹងភាពជាអ្នកដឹកនាំគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ជាពិសេសទំនួលខុសត្រូវរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត រួមជាមួយអង្គការដៃគូ ក្នុងការពង្រីកសក្តានុពលនៃអន្តរាគមន៍នានា ក៏ដូចជាធ្វើការសិក្សាស្រាវជ្រាវ និងជំរុញលើកទឹកចិត្តអ្នកសង្ស័យថាផ្ទុកមេរោគអេដស៍ឱ្យមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ដើម្បីឈានឆ្ពោះទៅសម្រេចបានគោលដៅ៩៥ទីមួយ។

តាមលទ្ធផលបឋមនៃការសិក្សាប៉ាន់ប្រមាណបែបវិទ្យាសាស្ត្រ ឆ្នាំ២០២៣ ទាក់ទងនឹងចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិបានរកឃើញថា រាជធានី ខេត្តដែលមានការឆ្លងមេរោគអេដស៍ថ្មីក្នុងចំណោមក្រុមប្រឈម មាន៦រាជធានី ខេត្តគឺ ៖ រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ និងខេត្តព្រះសីហនុ ដែលមានអត្រាឆ្លងរហូតដល់៧២% នៃការឆ្លងថ្មីនៅទូទាំងប្រទេស។ ក្នុងនោះ ខេត្តតាកែវ និងខេត្តព្រះសីហនុ គឺជាខេត្តពីរក្នុងចំណោមរាជធានី ខេត្ត៤ផ្សេងទៀត ដែលត្រូវបានរកឃើញថា មានអត្រានៃការឆ្លងមេរោគអេដស៍ថ្មីខ្ពស់ជាងគេ ក្នុងចំណោមប្រជាជនគន្លឹះ (ក្រុមប្រជាជនប្រឈមមុខខ្ពស់) រួមមាន បុរសរួមភេទជាមួយបុរស (MSM) ស្ត្រីបំប្លែងភេទ (TG) អ្នកបម្រើក្នុងសេវាកម្សាន្ត (EW) និងអ្នកប្រើប្រាស់គ្រឿងញៀន (PWID/PWUD)។ តាមការវិភាគក៏បានបង្ហាញថា កំណើននៃការឆ្លងមេរោគអេដស៍ថ្មី គឺស្ថិតក្នុងចំណោមបុរស និងក្មេងប្រុសមានចំនួន៧៩%។ ក្នុងនោះ ៨៣%នៃអ្នកឆ្លងថ្មី គឺជាក្រុមប្រឈម ឬជាក្រុមប្រជាជនគន្លឹះ។ ជាមួយគ្នានេះ ក្រុមបុរសរួមភេទជាមួយបុរសដែលជាយុវវ័យ ចំនួន៥០%ត្រូវបានរកឃើញថា មិនទទួលស្គាល់ថាខ្លួនជាអ្នកប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ឡើយ។ ដូច្នេះ យើងគប្បីត្រូវយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀត ក្នុងការពង្រីកសេវាគ្របដណ្តប់ និងអន្តរាគមន៍បង្ការឱ្យបានហ្មត់ចត់ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកាអង្គសន្និបាតជ្រាបថា យើងមានរបៀបវារៈចំនួន៥ ដើម្បីធ្វើបទបង្ហាញជូនអង្គសន្និបាត រួមមាន ៖ ១) ការចូលរួមរបស់សង្គមស៊ីវិល និងតំណាងប្រជាជនគន្លឹះអ្នកផ្ទុកមេរោគអេដស៍និងយុវវ័យ ៖ ក) ការបង្ហាញអ្នកមានស្នាដៃឆ្នើម និងខ)ការគាំទ្រដល់ប្រព័ន្ធជាតិ ឆ្លើយតបនឹងជំងឺអេដស៍ ដោយលោក ទឹម វ៉ា នាយកប្រតិបត្តិគណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព (HACC) ២) វឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ក្នុងវិស័យអប់រំ ដោយតំណាងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងអប់រំ យុវជន និងកីឡា ៣) ឱកាសនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ លើកទី៦ ៖ ក) ការពង្រឹងយន្តការសម្របសម្រួល ខ) ចលនាធនធាន គ) សមាហរណកម្មឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ក្នុងវិស័យសុខាភិបាល ឃ) វិមជ្ឈការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ និង ង) អន្តរាគមន៍លើយុវវ័យ មុននឹងបញ្ចប់ យើងនឹងធ្វើការបូកសរុបលទ្ធផលសន្និបាតនិងជំហានបន្ទាប់ ដោយលោកវេជ្ជបណ្ឌិត ទេព ណារុធ ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំមានជំនឿថា អង្គសន្និបាតរបស់យើងនឹងទទួលបានចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗ ដែលបានមកពីការអនុវត្តជាក់ស្តែងរបស់សមាជិក សមាជិកានៃអង្គសន្និបាត ដែលអាចយកទៅ

ប្រើប្រាស់ក្នុងការកែលម្អនិងអនុវត្តកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត របស់ខ្លួនឱ្យបានកាន់តែល្អប្រសើរថែមទៀត។

នៅទីបញ្ចប់នេះ ខ្ញុំសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និង អន្តរជាតិទាំងអស់ មានសុខភាពល្អ កម្លាំងមាំមួនដើម្បីចូលរួមពិភាក្សាឱ្យបានសកម្ម និងទទួលបាន លទ្ធផលទៅតាមកម្មវត្ថុដែលបានគ្រោងទុក។

ខ្ញុំសូមប្រកាសបើក "**សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២៣**" ចាប់ពីពេល នេះតទៅ។

សូមអរគុណ។